# ការថែទាំសុខភាពផ្នែកពន្យារកំណើត និងការយកកូនចេញសម្រាប់យុវវ័យ

## សេវាកម្មទូទៅ

### គ្លីនិកពិនិត្យសុខភាពយុវវ័យ និងមនុស្សពេញវ័យនៅក្មេងរបស់មន្ទីរពេទ្យកុមារនៃទីក្រុង LA (Children's Hospital LA Teen & Young Adult Health Clinic)



**គេហទំព័រ៖** https://www.chla.org/teenage-and-young-adult-health-clinic

សេវាកម្មទាក់ទងទៅនឹងការថែទាំផ្នែកមេរោគ HIV កង្វល់ផ្នែករដូវនិងរោគស្ត្រី សុខភាពបន្តពូជនិងមធ្យោបាយពន្យារកំណើតនានា រួមមានមធ្យោបាយពន្យារកំណើតដែលដំណើរការរយៈពេលវែងប៉ុន្តែអាចវិលត្រឡប់ថយក្រោយវិញបាន (long-acting reversible contraceptive methods) ហើយនិងការថែទាំសុខភាពអ្នកដែលបានប្តូរភេទខុសពីកំណើត (transgender) ផងដែរ **នៅទីតាំង Mid-Wilshire/Koreatown**។

### មណ្ឌលថែទាំសុខភាព Eisner (Eisner Health)



**គេហទំព័រ៖** https://www.eisnerhealth.org

មានផ្តល់សេវាកម្មថែទាំសុខភាពដែលចាំបាច់ សេវាកម្មថែទាំសុខភាពកុមារ និងសេវាកម្មថែទាំសុខភាពផ្លូវភេទជូនដល់អ្នកជំងឺគ្រប់អាយុ ដោយរួមមានសេវាកម្មរៀបចំផែនការគ្រួសារ ការធ្វើតេស្តរកនិងការព្យាបាលការឆ្លងមេរោគតាមផ្លូវភេទផ្សេងៗ (STIs) ហើយនិងការពិនិត្យមើលថាមានផ្ទៃពោះឬទេ ផងដែរ។ **មានទីតាំងនៅកណ្តាលទីក្រុង LA (Downtown LA) និងតំបន់ San Fernando Valley**។

### មណ្ឌលសុខភាពរបស់ស្ត្រី FPA (FPA Women's Health)

**គេហទំព័រ៖** https://www.fpawomenshealth.com/

ដោយមាន**ទីតាំងជាច្រើនកន្លែងនៅទូទាំងខោនធីនេះ** មណ្ឌលសុខភាព FPA ផ្តល់ជូនការថែទាំផ្នែកការយកកូនចេញ ការធ្វើតេស្តរកនិងការព្យាបាលការឆ្លងមេរោគតាមផ្លូវភេទផ្សេងៗ (STIs) ហើយនិងជម្រើសផ្នែកពន្យារកំណើតជាច្រើនប្រភេទ ផងដែរ។ **ការកំណត់ពេលវេលាណាត់ជួបគឺអាចធ្វើទៅបានតាមប្រព័ន្ធអនឡាញ**។



County of Los Angeles
Public Health
(Cambodian)

## មណ្ឌលសុខភាពស្ត្រី Her Smart Choice



គេហទំព័រ៖ https://hersmartchoice.com/

គ្លីនិកឯកជនផ្នែកការយកកូនចេញនៅក្នុង**តំបន់ Los Angeles ដែលមានទីតាំងចំនួនប្រាំពីរកន្លែង**។ គ្លីនិកនេះមានផ្តល់ជូនមធ្យោបាយពន្យារកំណើត ការយកកូនចេញដោយប្រើប្រាស់ថ្នាំពេទ្យ (medication abortion) ហើយនិងការធ្វើតេស្តរកនិងការព្យាបាលការឆ្លងមេរោគតាមផ្លូវភេទផ្សេងៗ (STIs) ផងដែរ។ **ការកំណត់ពេលវេលាណាត់ជួបគឺអាចធ្វើទៅបានតាមប្រព័ន្ធអនឡាញ។**

## គ្លីនិក Planned Parenthood នៅតំបន់ Los Angeles

គេហទំព័រ៖ https://www.plannedparenthood.org/planned-parenthood-los-angeles

ដោយមាន**ទីតាំងនៅទូទាំងខោនធី LA** គ្លីនិក Planned Parenthood នៅតំបន់ LA មានផ្តល់ជូនសេវាកម្មផ្នែកសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមមានការធ្វើតេស្តរកនិងការព្យាបាលការឆ្លងមេរោគតាមផ្លូវភេទផ្សេងៗ (STIs) មធ្យោបាយពន្យារកំណើត ការធ្វើតេស្តត្រួតពិនិត្យកស្សនរកជំងឺមហារីក (pap tests) ការយកកូនចេញ ហើយនិងការចាក់ថ្នាំបង្ការផ្សេងៗ ផងដែរ។ **ការកំណត់ពេលណាត់ជួបគឺអាចធ្វើទៅបានតាមប្រព័ន្ធអនឡាញ ហើយមានយុវវ័យជាអ្នកឯកទេសសម្រាប់ជួយតាមទូរស័ព្ទដល់ការកំណត់ពេលវេលាណាត់ជួប ផងដែរ។**

## គ្លីនិក Planned Parenthood នៅតំបន់ Pasadena និងតំបន់ San Gabriel Valley

គេហទំព័រ៖ https://www.plannedparenthood.org/planned-parenthood-pasadena-san-gabriel-valley

គ្លីនិកទាំងឡាយ**មានទីតាំងនៅប៉ែកខាងកើតនៃខោនធី LA**។ មានផ្តល់ជូនការត្រួតពិនិត្យសុខភាពការពារទុកជាមុន មធ្យោបាយពន្យារកំណើត ការធ្វើតេស្តរកនិងការព្យាបាលការឆ្លងមេរោគតាមផ្លូវភេទផ្សេងៗ (STIs) ការយកកូនចេញ ព្រមទាំងថ្នាំសម្រាប់ទប់ស្កាត់ជំងឺ មុនពេលប៉ះពាល់ទៅនឹងមេរោគ (Pre-Exposure Prophylaxis/PrEP) និងថ្នាំទប់ស្កាត់ជំងឺ ក្រោយពេលប៉ះពាល់ទៅនឹងមេរោគរួច (Post Exposure Prophylaxis/PEP)។ **ការកំណត់ពេលវេលាណាត់ជួបគឺអាចធ្វើទៅបានតាមប្រព័ន្ធអនឡាញ ហើយមានយុវវ័យជាអ្នកឯកទេសសម្រាប់ជួយតាមទូរស័ព្ទដល់ការកំណត់ពេលវេលាណាត់ជួប ផងដែរ។**

## មណ្ឌលសុខភាពគ្រួសារ Westside (Westside Family Health Center)

គេហទំព័រ៖ https://www.wfhcenter.org/

**មានទីតាំងនៅក្នុងទីក្រុង Culver City** មណ្ឌលសុខភាពគ្រួសារ Westside មានផ្តល់ជូនសេវាកម្មផ្នែកសុខភាពបន្តពូជ រួមមានការរៀបចំផែនការគ្រួសារ និងការថែទាំផ្នែករោគស្ត្រី ដែលក្នុងនោះមានមធ្យោបាយពន្យារកំណើត ការពិនិត្យមើលថាមានផ្ទៃពោះឬទេ ការធ្វើតេស្តរកនិងការព្យាបាលការឆ្លងមេរោគតាមផ្លូវភេទផ្សេងៗ (STIs) ហើយនិងសេវាកម្មផ្នែកការបញ្ជូនឈ្មោះ ផងដែរ។

## គ្លីនិកសុខភាពគ្រួសារ Venice (Venice Family Clinic)

គេហទំព័រ៖ https://venicefamilyclinic.org/

គ្លីនិកសុខភាពគ្រួសារ Venice មាន**ទីតាំងជាច្រើនកន្លែងនៅតំបន់ប៉ែកខាងលិចនៃខោនធី LA និងនៅក្នុងតំបន់ South Bay** ហើយមានផ្តល់ជូនការប្រឹក្សាផ្នែកការពន្យារកំណើត ការថែទាំផ្នែកផ្ទៃពោះ ការធ្វើតេស្តពិនិត្យសុខភាពផ្លូវភេទ ហើយនិងការព្យាបាលដោយការដាក់បន្ថែមអ័រម៉ូន (hormonal therapy) ផងដែរ។



# សេវាកម្មពិសេសៗ

## កម្មវិធីជីវិតក្រុមគ្រួសារនៃមនុស្សវ័យជំទង់របស់សេវាកម្មថែទាំសុខភាព Alta Med (Alta Med Health Services – Adolescent Family Life Program)

គេហទំព័រ៖ https://www.altamed.org/youth-services

ភ្ជាប់ទំនាក់ទំនង**យុវវ័យដែលមានផ្ទៃពោះ និងឪពុកម្ដាយដែលមានអាយុក្រោម 22 ឆ្នាំ** ទៅនឹងអ្នកគ្រប់គ្រងសំណុំរឿង (case manager) ម្នាក់ ដើម្បីផ្ដោតគំនិតទៅលើការលូតលាស់ក្នុងលក្ខណ:វិជ្ជមានសម្រាប់យុវវ័យ (ដូចជាការកំណត់ចំណុចខ្លាំងទាំងឡាយ ការស្រាវជ្រាវរកគុណសម្បត្តិ ការចាត់តាំងគោលដៅ និងការបង្កើតជំនាញផ្សេងៗ ជាដើម)។

## មជ្ឈមណ្ឌលសម្រាប់អ្នក LGBT នៃទីក្រុង Los Angeles (Los Angeles LGBT Center)

គេហទំព័រ៖ https://lalgbtcenter.org/

មានផ្ដល់ជូន**សេវាកម្មជាច្រើនប្រភេទសម្រាប់យុវវ័យដែលជាស្រីស្រឡាញ់ស្រី (lesbian) ជាប្រុសស្រឡាញ់ប្រុស (gay) ជាអ្នកស្រឡាញ់ទាំងពីរភេទ (bisexual) ជាអ្នកប្ដូរភេទខុសពីកំណើត (transgender) ជាអ្នកមិនស្រឡាញ់ភេទផ្ទុយគ្នា (queer) និងអ្នកមិនច្បាស់លាស់អំពីភេទរបស់ខ្លួន (questioning)** រួមមានការថែទាំសុខភាពបន្ថ្ពូជ ការថែទាំសុខភាពសម្រាប់ការប្ដូរភេទខុសពីកំណើត ហើយនិងសេវាកម្មផ្សេងៗផ្នែកផ្ទះសម្បែងនិងការបញ្ជូនឈ្មោះ។ មានគ្លីនិកចំនួនប្រាំបីកន្លែងផ្សេងគ្នានៅទូទាំងទីក្រុង ដោយរួមមានមជ្ឈមណ្ឌលសម្រាប់យុវវ័យ (youth center) ផងដែរ។

## គ្លីនិករបស់មជ្ឈមណ្ឌលថែទាំសុខភាពកុមារ (Pediatric Medical Hub Clinics)

គេហទំព័រ៖ https://dhs.lacounty.gov/medical-hubs/our-services/home/

គ្លីនិករបស់មជ្ឈមណ្ឌលថែទាំសុខភាពនៃខោនធី Los Angeles (Los Angeles County Medical Hub Clinics) មានផ្ដល់ជូនការថែទាំសុខភាពដែលមានគុណភាពខ្ពស់ ហើយដែលមានការសម្របសម្រួលត្រឹមត្រូវ ដោយរួមមានការថែទាំផ្នែកសុខភាពបន្តពូជផងដែរនោះ សម្រាប់**មនុស្សវ័យក្មេងដែលមានការពាក់ព័ន្ធជាមួយនឹងនាយកដ្ឋានសេវាកម្មសម្រាប់កុមារ និងក្រុមគ្រួសារ (Department of Children and Family Services/DCFS)**។

មជ្ឈមណ្ឌលគឺមានទីតាំងចំនួនប្រាំពីរកន្លែង៖

- ♦**មណ្ឌលថែទាំសុខភាព Harbor-UCLA (Harbor-UCLA Medical Center)**
- ♦**មណ្ឌលសុខភាពក្នុងតំបន់ High Desert (High Desert Regional Health Center)**
- ♦**មណ្ឌលសម្រាប់អ្នកជំងឺមិនសម្រាកព្យាបាល MLK Jr. (MLK Jr. Outpatient Center)**
- ♦**មណ្ឌលថែទាំសុខភាពទូទៅនៃខោនធី LA (LA General Medical Center)**
- ♦**គ្លីនិកនៅតំបន់ East San Gabriel Valley (East San Gabriel Valley Clinic)**
- ♦**មណ្ឌលថែទាំសុខភាព Olive View-UCLA (Olive View-UCLA Medical Center)**
- ♦**មន្ទីរពេទ្យកុមារនៃទីក្រុង LA (Children's Hospital LA/CHLA)**



# មណ្ឌលសុខភាពនៅតាមសាលារៀន

គ្លីនិកទាំងឡាយខាងក្រោមនេះ**មានទីតាំងនៅខាងក្នុងសាលារៀន** ហើយអាចប្រើប្រាស់បានដោយសិស្ស នៅតាមសាលារៀនទាំងនោះ តែប៉ុណ្ណោះ។

ក្នុងចំណោមនេះ គ្លីនិកមួយចំនួនមានផ្តល់សេវាកម្មផ្សេងៗជូនដល់សមាជិកក្រុមគ្រួសាររបស់សិស្ស ទាំងឡាយដែលកំពុងសិក្សានៅទីនោះផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីគ្លីនិកផ្សេងៗ សូមចូលទៅកាន់គេហទំព័រ៖ https://www.lausd.org/Page/12532។

## គ្លីនិកនៅតាមសហគមន៍ដែលជាដៃគូ (Community Clinic Partnership)

- មណ្ឌលថែទាំសុខភាព Harbor-UCLA នៅវិទ្យាល័យ Gardena (Harbor-UCLA at Gardena High School)
  **គេហទំព័រ៖ https://bit.ly/gardenahscommclinic | លេខទូរស័ព្ទ៖ (424) 306-8280**
- មណ្ឌលថែទាំសុខភាព St. John's នៅក្នុងមណ្ឌលថែទាំសុខភាពរបស់វិទ្យាល័យ Theodore Roosevelt (St. John's Wellness Center at Theodore Roosevelt High School Wellness Center)
  **គេហទំព័រ៖ https://bit.ly/4btscms | លេខទូរស័ព្ទ៖ (323) 541-1400**

## មណ្ឌលថែទាំសុខភាពរបស់ LAUSD និង LA Trust (LAUSD and LA Trust Wellness Center)

**គេហទំព័រ៖ https://www.lausd.org/Page/18488**

មណ្ឌលថែទាំសុខភាពសម្រាប់សិស្ស និងក្រុមគ្រួសាររបស់ LA Trust (LA Trust Student & Family Wellness Center) មានទីតាំងនៅខាងក្នុងសាលារៀនទាំងឡាយខាងក្រោមនេះ៖

- វិទ្យាល័យ Belmont
- វិទ្យាល័យ Carson
- វិទ្យាល័យ Crenshaw
- មណ្ឌលសិក្សា Elizabeth (Elizabeth Learning Center)
- សាលារៀនដែលមានកម្មវិធីសិក្សាលក្ខណ: ឯកទេស MaCES (Maywood Center for Enriched Studies Magnet School)
- វិទ្យាល័យ Fremont
- អនុវិទ្យាល័យ Gage
- វិទ្យាល័យ Garfield
- វិទ្យាល័យ Hollywood
- វិទ្យាល័យ Jefferson
- មណ្ឌលថែទាំសុខភាព Santee (Santee Wellness Center)
- វិទ្យាល័យ Sylvia Mendez
- អនុវិទ្យាល័យ Maclay
- វិទ្យាល័យ Manual Arts
- មណ្ឌលថែទាំសុខភាព North Hills នៅវិទ្យាល័យ James Monroe
- វិទ្យាល័យ Washington Prep

## មណ្ឌលថែទាំសុខុមាលភាពរបស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA (LA County Department of Public Health Wellbeing Centers)

ដោយមានទីតាំងនៅក្នុងបរិវេណវិទ្យាល័យជាច្រើន មណ្ឌលថែទាំសុខុមាលភាព (Wellbeing Centers) គឺជាទីកន្លែងមានការទទួលស្វាគមន៍ដែលសិស្សទាំងឡាយអាចបន្ធូរអារម្មណ៍បាន ហើយនិងអាចទទួលបានព័ត៌មាននិងសេវាកម្មផ្សេងៗសម្រាប់ប្រធានបទផ្នែកសុខភាពជាច្រើនប្រភេទ ផងដែរ។ មានអារម្មណ៍តានតឹងឬ? មានអារម្មណ៍សោកសៅរបស់ឬ? ចង់ដឹងបន្ថែមទៀតអំពីវិធីទប់ស្កាត់ការឆ្លងមេរោគតាមផ្លូវភេទ (STI) ឬ? ចង់ពិភាក្សាជាមួយនឹងនរណាម្នាក់អំពីការទំនាក់ទំនងរបស់អ្នកជាមួយនឹងអ្នកដទៃឬ? ត្រូវការព័ត៌មានបន្ថែមអំពីថ្នាំបំបាត់ការឈឺចាប់ដែលអាចញៀនបានប្រភេទ fentanyl ឬក៏អំពីរបៀបជួយដល់មិត្តភក្តិម្នាក់ឱ្យកាត់បន្ថយការជក់បារីអេឡិចត្រូនិច (vaping) ឬ? ចង់ដឹងថាតើអាចរកថ្នាំពន្យារកំណើតបែបបន្ទាន់ (emergency contraception) នៅទីណាឬ?

**សូមស្វែងយល់ថាតើសាលារៀនរបស់អ្នកមានមណ្ឌលថែទាំសុខុមាលភាពឬទេ ដោយសាកសួរទៅកាន់ការិយាល័យធំរបស់សាលារៀនអ្នក ឬក៏ដោយការទាក់ទងទៅកាន់អង្គភាពវិស័យអប់រំ (Education Sector Unit) នៅនាយកដ្ឋានសុខភាពសាធារណ: តាមរយ:អ៊ីម៉ែល៖ dph-education@ph.lacounty.gov។**

*នេះគឺជាឯកសារធនធានដែលមានការធ្វើឱ្យថ្មីឡើងវិញជាប្រចាំ ហើយមិនមែនជាឯកសារបញ្ជីដែលពេញលេញនោះទេ។ ប្រសិនបើអ្នកចង់ឱ្យដាក់បញ្ចូលព័ត៌មានទាក់ទងទៅនឹងមណ្ឌលសុខភាពនៅសាលារៀនរបស់អ្នក ឬចង់ធ្វើឱ្យព័ត៌មានបានត្រឹមត្រូវទាន់ហេតុការណ៍នោះ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយ:អ៊ីម៉ែល៖ owh@ph.lacounty.gov។*

County of Los Angeles Public Health

# ធនធានផ្សេងៗទាក់ទងទៅនឹងសុខភាពបន្តពូជ

## Pocket Guide LA

**គេហទំព័រ៖**
**https://www.pocketguidela.org/**
គេហទំព័រនេះផ្តល់ជូនព័ត៌មានដែលអាចអនុវត្តចំពោះស្ថានភាពជាច្រើនបានទាក់ទងទៅនឹងគ្លីនិកទាំងឡាយនៅក្នុងទីក្រុង LA ដែលមានផ្តល់ជូនសេវាកម្មផ្នែកសុខភាពបន្តពូជដល់យុវវ័យ។ គេហទំព័រនេះក៏មានព័ត៌មានទាក់ទងទៅនឹងការរក្សាការសម្ងាត់ និងសិទ្ធិផ្សេងៗរបស់យុវវ័យ ផងដែរ។

## ScarletTeen

**គេហទំព័រ៖**
**https://www.scarleteen.com/**
មានផ្តល់ជូនព័ត៌មានទាក់ទងទៅនឹងផ្លូវភេទ និងការទំនាក់ទំនងជាមួយនឹងអ្នកដទៃក្នុងលក្ខណៈមានការគិតគូរហើយដែលពេញលេញ និងដែលមានការគាំទ្រជូនដល់ក្មេងជំទង់ និងមនុស្សពេញវ័យដែលមិនសូវមានបទពិសោធន៍ជីវិត។

## TeenSource+

**គេហទំព័រ៖**
**https://www.teensource.org/**
គេហទំព័រមួយដែលធ្វើការអប់រំដល់មនុស្សវ័យក្មេងទាំងឡាយអំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ សេវាកម្មមិនគិតថ្លៃព្រមទាំងរក្សាការសម្ងាត់ដែលពួកគេអាចប្រើប្រាស់បាន ហើយនិងសិទ្ធិផ្សេងៗរបស់ពួកគេក្នុងការទទួលបានការថែទាំ ការទទួលខុសត្រូវលើសុខភាពរបស់ពួកគេ ក៏ដូចជាការបង្កើតទំនាក់ទំនងជាមួយនឹងអ្នកដទៃដែលប្រកបដោយការគោរព និងការជឿជាក់ ផងដែរ។



## Reproductive Health Equity Project

**គេហទំព័រ៖**
**https://fosterreprohealth.org/**
គម្រោងដើម្បីទទួលបានភាពសមរម្យនិងយុត្តិធម៌ទាក់ទងទៅនឹងសុខភាពបន្តពូជ (RHEP) សម្រាប់យុវវ័យស្ថិតក្រោមការចិញ្ចឹមមើលថែទាំនេះភ្ជាប់ទំនាក់ទំនងយុវវ័យដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំ (foster care) ជាមួយនឹងទីភ្នាក់ងារទាំងឡាយដែលបម្រើការជូនដល់ពួកគេ ដើម្បីលើកកម្ពស់ដល់ប្រព័ន្ធដំណើរការផ្សេងៗដែលធ្វើឱ្យមានលក្ខណៈធម្មតា គាំទ្រ និងលើកកម្ពស់ដល់ការមានសិទ្ធិម្ចាស់ការលើរាងកាយហើយនិងការយល់ដឹងផ្នែកផ្លូវភេទដែលត្រឹមត្រូវនិងសមរម្យសម្រាប់យុវវ័យស្ថិតក្រោមការចិញ្ចឹមមើលថែទាំ។

## Talk With Your Kids

**គេហទំព័រ៖**
**https://www.talkwithyourkids.org/**
គេហទំព័រ Talk With Your Kids ផ្តល់ជូនព័ត៌មាន ដើម្បីបង្កើតជំនឿចិត្តដល់ឪពុកម្តាយ និងក្រុមគ្រួសារទាំងឡាយក្នុងការចាប់ផ្តើមការសន្ទនាផ្សេងៗដែលសក្តិសមទៅនឹងអាយុ និងដោយផ្អែកទៅលើការពិតជាមួយនឹងកូនៗរបស់ពួកគេអំពីការទំនាក់ទំនងជាមួយនឹងអ្នកដទៃ អំពីការរួមភេទ អំពីការលូតលាស់ និងអំពីចំណុចជាច្រើនទៀត។



# ធនធានផ្សេងៗទាក់ទងទៅនឹងច្បាប់ផ្នែកសុខភាពរបស់យុវវ័យ

## មជ្ឈមណ្ឌលជាតិសម្រាប់ច្បាប់របស់យុវវ័យ (National Center for Youth Law)

**គេហទំព័រ៖ https://youthlaw.org/**

មជ្ឈមណ្ឌលជាតិសម្រាប់ច្បាប់របស់យុវវ័យ (NCYL) ផ្តល់មធ្យោបាយ វគ្គបង្ហាត់ និងធនធានផ្សេងៗជូនដល់យុវវ័យ ឪពុកម្តាយ និងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយ ដើម្បីជួយពួកគេក្នុងការស្វែងរកទិសដៅទាក់ទងទៅនឹងបំណងប្រាថ្នាដែលកាន់តែធំទៅរបស់យុវវ័យក្នុងការទទួលបានការលាក់កំបាំងកាន់តែច្រើនឡើងនោះ ហើយដែលមូលហេតុនេះធ្វើឱ្យដៃគូផ្តល់ការថែទាំ និងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយមានអារម្មណ៍ថាពិបាក។

## ច្បាប់ផ្នែកសុខភាពរបស់យុវវ័យ (Teen Health Law)

**គេហទំព័រ៖ https://teenhealthlaw.org/consent/**

ឯកសារជំនួយនៅលើគេហទំព័រនេះធ្វើការសង្ខេបអំពីសិទ្ធិរបស់អនីតិជន (ជនមិនទាន់គ្រប់អាយុ) និងភាគីទីបីក្នុងការផ្តល់ការអនុញ្ញាតចំពោះការថែទាំសុខភាពរបស់អនីតិជននៅក្នុងរដ្ឋ California។

## កម្មវិធីថ្នាក់ជាតិអំពីច្បាប់ផ្នែកសុខភាព (National Health Law Program/NHeLP)

**គេហទំព័រ៖ https://healthlaw.org/resource/resources-for-california-foster-youth-sexual-reproductive-and-mental-health-medi-cal-services/**

យុវវ័យដែលជាអ្នកកំពុងស្ថិតក្រោមការចិញ្ចឹមមើលថែទាំ (foster care) និងអ្នកដែលធ្លាប់បានស្ថិតក្រោមការចិញ្ចឹមមើលថែទាំពីពេលកន្លងមក ហើយដែលជាសមាជិកកម្មវិធីធានារ៉ាប់រង Medi-Cal នោះ អាចទទួលប្រើប្រាស់សេវាកម្មជាច្រើនប្រភេទផ្នែកសុខភាពបន្តពូជ ផ្នែកសុខភាពផ្លូវភេទ និងផ្នែកសុខភាពផ្លូវចិត្តបាន។ NHeLP បានបង្កើតសំណុំឯកសាររូបភាពក្រាហ្វិកដែលមានផ្ទុកព័ត៌មាន និងតារាងព័ត៌មានការពិតផ្សេងៗក្នុងគោលបំណងជួយដល់យុវវ័យដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំឱ្យយល់ដឹងបានកាន់តែច្បាស់លាស់អំពីសេវាកម្មផ្សេងៗដែលមានសម្រាប់ផ្តល់ជូនដល់ពួកគេតាមរយៈកម្មវិធីធានារ៉ាប់រង Medicaid របស់រដ្ឋ California ដែលអាចអនុវត្តចំពោះស្ថានភាពជាច្រើនបាននេះ។



**សូមស្កេនកូដ QR នេះ សម្រាប់ព័ត៌មានបន្ថែមអំពីការយកកូនចេញ និងការពន្យារកំណើត។**